ត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនៅបរទេស រហូតដល់ពេលឯកឧត្តមអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **អ៊ឹម ឈុនលឹម** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សេចក្តីសម្រេចលេខ ៤៦ សសរ

## ស្តីពីការបន្ថែមសមាសភាព នៃគណៈកម្មាធិការទទួលជនភៀសខ្លួន និងសមាហរណកម្មកំលាំងផ្តាច់ខ្លួន

★★★

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្តីសម្រេចលេខ ៤៣ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការទទួលជនភៀសខ្លួន និង សមាហរណកម្មកងកំលាំងផ្តាច់ខ្លួន
- តាមការចាំបាច់របស់សង្គមជាតិ

### សម្រេច

ប្រការ ១ : ត្រូវបានបន្ថែមសមាសភាពនៅក្នុងប្រការ១ នៃសេចក្តីសម្រេចលេខ ៤៣ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីបង្កើតគណៈកម្មាធិការទទួលជនភៀសខ្លួន និងសមាហរណកម្មកងកំលាំងផ្តាច់ខ្លួន :

-ឯកឧត្តម **អ៊ុជ គឹមអន** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

ប្រការ ២ : ត្រូវបានបន្ថែមសមាសភាពនៅក្នុងប្រការ ៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការទទួលបន្ទុកជនភៀសខ្លួន :

-លោក សោម សុនណា អនុប្រធាននាយកដ្ឋានអន្តរជាតិក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សមាជិក

-ត្រូវបានបន្ថែមសមាសភាពនៅក្នុងប្រការ ៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការទទួលបន្ទុកសមាហរណកម្មកំពង់ផ្ទាត់ខ្លួន :

-លោកឧត្តមសេនីយ៍ត្រី ម៉ៅ ច័ន្ទណារិន ប្រធាននាយកដ្ឋានបុគ្គលិកនគរបាលក្រសួងមហាផ្ទៃ សមាជិក

-លោកឧត្តមសេនីយ៍ត្រី ងាម គិន នាយកនាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ សមាជិក

-ប្រធានការិយាល័យទី២ នៃអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ សមាជិក

-ត្រូវបានបន្ថែមសមាសភាពនៅក្នុងប្រការ៦ស្តីពីការបង្កើតអនុគណៈកម្មាធិការផ្គត់ផ្គង់កំលាំងសមាហរណកម្ម :

-លោកឧត្តមសេនីយត្រី ស៊ុំ សំណាង នាយកនាយកដ្ឋានផ្គត់ផ្គង់ក្រសួងការពារជាតិ សមាជិក

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានស្ថាប័នពាក់ព័ន្ធ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១-២ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៦៨៤ ឧក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

★ ★ ★

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា